Australian Government
Aged Care Quality and Safety Commission

Engage
*Empower*
**Safeguard**

ជូនចំពោះភ្ញៀវទទួលសេវាកម្មជរាវ័យ(aged care)

ខ្ញុំកំពុងសរសេរលិខិតនេះដើម្បីប្រាប់លោកអ្នកអំពីការផ្លាស់ប្តូរសំខាន់ៗដែលនឹងធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាព និងគុណភាពនៃការថែទាំមនុស្ស
ចាស់។ លោកអ្នកមិនចាំបាច់ឆ្លើយតបទៅនឹងលិខិតនេះទេ។

រដ្ឋាភិបាលអូស្ត្រាលីកំពុងផ្តោតការយកចិត្តទុកដាក់លើការដោះស្រាយអនុសាសន៍សំខាន់ៗរបស់គណកម្មាធិការគុណភាព និងសុវត្ថិភាពនៃការថែទាំមនុស្សចាស់ (Royal Commission into Aged Care Quality and Safety)។

ការផ្លាស់ប្តូរមួយចំនួនចាប់ផ្តើមនៅថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2022។
សេវាថែទាំមនុស្សចាស់នឹងត្រូវបំពេញតាមតម្រូវការថ្មីចាប់ពីកាលបរិច្ឆេទនោះតទៅ។ គណកម្មាធិការគុណភាព និងសុវត្ថិភាពនៃការថែទាំមនុស្សចាស់ (គណៈកម្មការ)
នឹងមានអំណាចបន្ថែមទៀតក្នុងការធ្វើឱ្យប្រាកដថាអ្នកដែលផ្តល់
សេវាថែទាំមនុស្សចាស់បានបំពេញនូវទំនួលខុសត្រូវរបស់ពួកគេ។

ការផ្លាស់ប្តូរដែលចាប់ផ្តើមនៅថ្ងៃទី 1 ខែធ្នូ រួមមាន៖

- ការកែលម្អវិធីដែលសេវាថែទាំមនុស្សចាស់ដំណើរការ។
  នេះរាប់បញ្ចូលទាំងសេវាថែទាំមនុស្សចាស់នៅតាមលំនៅដ្ឋានដែលសួរអ្នកប្រើប្រាស់ថាតើពួកគេចង់មានគណៈកម្មាធិការប្រឹក្សាអ្នកប្រើប្រាស់ (Consumer Advisory Committee)
  ដើម្បីផ្តល់ឱ្យលោកអ្នកដែលប្រើប្រាស់សេវាកម្មនិយាយអំពីរបៀបដែលពួកគេដំណើរការដែរ ឬ ទេ។
- ក្រមសីលធម៌ (Code of Conduct)
  ថ្មីដែលនិយាយអំពីរបៀបដែលប្រជាជនទទួលបន្ទុកសេវាថែទាំមនុស្សចាស់
  និងអ្នកថែទាំវ័យចំណាស់របស់ពួកគេ ត្រូវតែអនុវត្តចំពោះមនុស្សដែលទទួលការថែទាំ។
  គណៈកម្មាការនឹងមានអំណាចដើម្បីចាត់វិធានការក្នុងករណីដែលអ្នកផ្តល់សេវា ឬ
  បុគ្គលិកបំពានក្រមសីលធម៌នោះ។
- គ្រោងការណ៍ឆ្លើយតបឧបទ្ទវហេតុធ្ងន់ធ្ងរ (Serious Incident Response Scheme)
  ដែលអនុវត្តចំពោះការថែទាំមនុស្សចាស់ដែលមាននៅក្នុងផ្ទះ ឬ សហគមន៍។
  អ្នកផ្តល់សេវាទាំងអស់នឹងត្រូវបង្ហាញថាពួកគេមានវិធីសាស្ត្រដើម្បីកាត់បន្ថយហានិភ័យនៃអ្វីដែលខុស និងអាចឆ្លើយតបបានយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព
  ប្រសិនបើមានអ្វីមួយខុសប្រក្រតីដែលប៉ះពាល់ដល់អ្នកប្រើប្រាស់។ ឥឡូវនេះ
  អ្នកផ្តល់សេវាថែទាំតាមផ្ទះក៏នឹងត្រូវរាយការណ៍អំពីឧប្បត្តិហេតុធ្ងន់ធ្ងរទៅគណៈកម្មការ
  និងចាត់វិធានការដើម្បីប្រាកដថាពួកគេមិនកើតឡើងម្តងទៀត។
  (អ្នកផ្តល់សេវាថែទាំមនុស្សចាស់ដែលមានលំនៅដ្ឋានត្រូវបានតម្រូវឱ្យធ្វើកិច្ចការនេះរួចហើយ។ )

វានឹងមានការផ្លាស់ប្តូរកាន់តែច្រើនក្នុងឆ្នាំ 2023 ខាងមុខ
រួមទាំងការកែលម្អស្តង់ដារគុណភាពនៃការថែទាំមនុស្សចាស់ផងដែរ (Aged Care Quality Standards)។

គណៈកម្មាការនឹងធ្វើការជាមួយអ្នកផ្តល់សេវាថែទាំមនុស្សចាស់
ដើម្បីប្រាកដថាការផ្លាស់ប្តូរត្រូវបានធ្វើឡើងដោយរលូន។
អ្នកផ្តល់សេវារបស់អ្នកគួរប្រាប់លោកអ្នកផងដែរអំពីអ្វីដែលពួកគេកំពុងធ្វើ។.

លោកអ្នកមិនចាំបាច់ធ្វើអ្វីដើម្បីឆ្លើយតបនឹងលិខិតនេះទេ។ យើងនឹងផ្តល់ព័ត៌មានលម្អិតបន្ថែមទៀត
សម្រាប់អ្នកដែលទទួលការថែទាំ និងក្រុមគ្រួសាររបស់ពួកគេនៅពេលជិតកៀកដល់ថ្ងៃ 1 ខែធ្នូ។
ប្រសិនបើអ្នកចង់បន្តទំនាក់ទំនងជាមួយយើង អ្នកអាចចូលមើលគេហទំព័ររបស់យើង
ហើយចុះឈ្មោះទទួលព្រឹត្តិបត្រស្តីពីគុណភាពការថែទាំមនុស្សចាស់ប្រចាំខែ។

ខ្ញុំសង្ឃឹមថាសំបុត្រនេះបានបង្កើនទំនុកចិត្តរបស់លោកអ្នកថាអ្នកផ្តល់សេវាថែទាំមនុស្សចាស់របស់អ្នក
ហើយគណៈកម្មាការកំពុងខិតខំប្រឹងប្រែងដើម្បីធានាថាលោកអ្នកនឹងទទួលបាននូវបទពិសោធន៍ដ៏ល្អបំផុតនៃការថែទាំមនុស្សចាស់។

ដោយការគោរព

J. M. Anderson

Janet Anderson PSM

Commissioner

31 August 2022